# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧

# ការប្រកាសបើកកម្មវិធីអាហារូបករណ៍ទៅសិក្សានៅប្រទេសអូស្ត្រាលី សំរាប់ឆ្នាំ២០១៨

នៅថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ២០១៧ លោកជំទាវ **អេនជេលឡា ខកខឺរ៉េន** ឯកអគ្គរាជទូតអូស្ត្រាលី ប្រចាំកម្ពុជា និង ឯកឧត្តមបណ្ឌិត **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិង កីឡា នឹងរួមគ្នាបើកជាផ្លូវការនូវកម្មវិធីអាហារូបករណ៍ ដើម្បីបន្តការសិក្សានៅប្រទេសអូស្ត្រាលីសំរាប់ឆ្នាំ ២០១៨។

អាហារូបករណ៍អូស្ត្រាលី គឺជាអាហារូបករណ៍ដែលមានកិត្យានុភាពលំដាប់អន្តរជាតិ ផ្តល់ដោយរដ្ឋាភិបាលអូស្ត្រាលី សំរាប់អនាគតអ្នកដឹកនាំពិភពលោកជំនាន់ក្រោយ។ អាហារូបករណ៍អូស្ត្រាលី ផ្តល់ឱកាសដល់និស្សិតកម្ពុជា បានទៅសិក្សាថ្នាក់ក្រោយឧត្តមនៅប្រទេសសកលវិទ្យាល័យនានា ក្នុងប្រទេសអូស្ត្រាលី។

លោកជំទាវ **អេនជេលឡា ខកខឺរ៉េន** មានប្រសាសន៍ថា៖ " វិស័យអប់រំ គឺជាផ្នែកមួយដ៏សំខាន់ នៃទំនាក់ទំនងទ្វេភាគី រវាងកម្ពុជានិង អូស្ត្រាលី ។"

លោកជំទាវ បន្តទៀតថា៖ " អាហារូបករណ៍អូស្ត្រាលី ផ្តល់ឱកាសដល់ប្រជាជនកម្ពុជាអោយបានទៅសិក្សា នៅថ្នាក់ឧត្តមសិក្សាលំដាប់ពិភពលោក តាមរយៈការរស់នៅ សិក្សា និងជួបជាមួយមិត្តថ្មីៗនៅក្នុងទីក្រុងដ៏ស្រស់ស្អាត ទំនើប និងពោរពេញទៅដោយជាតិសាសន៍ចំរុះ ក្នុងប្រទេសអូស្ត្រាលី។"

អតីតនិស្សិតកម្ពុជាមកពីអូស្ត្រាលីជាច្រើនរូប បានក្លាយជាអ្នកដឹកនាំនៅក្នុងវិស័យការងាររបស់ពួកគេ ខ្លះបានក្លាយទៅជា រដ្ឋមន្ត្រី មន្ត្រីជាន់ខ្ពស់ ក៏ដូចជា នាយកប្រត្តិបត្តិ អ្នកគ្រប់គ្រង អគ្គនាយក និងអ្នកស្រាវជ្រាវ។

16B National Assembly Street, Sangkat Tonle Bassac Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

នៅក្នុងកម្មវិធីនោះដែរ លោកជំទាវឯកអគ្គរាជទូតនិង ឯកឧត្តមបណ្ឌិត **ហង់ ជួនណារ៉ុន** ក៏នឹងធ្វើការស្វាគមន៍នូវការវិលត្រលប់មកកាន់មាតុភូមិវិញ នៃនិស្សិតអាហារូបករណ៍អូស្ត្រាលីចំនួន៦១រូប ដែលបានបញ្ចប់ការសិក្សាដោយជោគជ័យពីប្រទេសអូស្ត្រាលីកាលពីឆ្នាំ២០១៦។

អាហារូបករណ៍អូស្ត្រាលីសំរាប់ឆ្នាំ២០១៨ នឹងបើកទទួលពាក្យចាប់ពី ថ្ងៃទី១ ខែកុម្ភៈ រហូតដល់ថ្ងៃទី ៣០ មេសា ឆ្នាំ២០១៧។ សូមលើកទឹកចិត្ត ដល់បេក្ខជនដែលចង់សិក្សាលើគ្រប់ផ្នែកទាំងអស់អោយចូលរួមដាក់ពាក្យ។

កម្មវិធីអាហារូបករណ៍អូស្ត្រាលី បើកទទួលពាក្យពីបេក្ខជនទាំងអស់ដែលមកពី ស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងវិស័យឯកជនផងដែរ។ រដ្ឋាភិបាលអូស្ត្រាលីបានប្តេជ្ញាចិត្ត ក្នុងការផ្តល់ឱកាសជូនដល់មនុស្សគ្រប់គ្នា ហើយយើងសូមលើកទឹកចិត្តជាពិសេសដល់ ស្ត្រី ជនពិការ និងបេក្ខជនដែលមកពីតាមបណ្តាខេត្តនានា ក្នុងការដាក់ពាក្យ ។

ព័ត៌មានបន្ថែមអំពីអាហារូបករណ៍អូស្ត្រាលី សូមចូលទៅវេបសាយ www.australiaawards.gov.au
ទំនាក់ទំនងព័ត៌មាន៖ Australian.Embassy.Cambodia@dfat.gov.au